អង្កេតលើ
ការផ្សព្វផ្សាយ
ព័ត៌មានថវិកា
ឆ្នាំ២០១៩

# ប្រទេសកម្ពុជា

## ទិដ្ឋភាពទូទៅ



**តម្លាភាពថវិកា**

**32** /100



**ការចូលរួមជាសាធារណៈ**

**6** /100



**ការត្រួតពិនិត្យថវិកា**

**50** /100

## អំពីការស្ទង់មតិ

ការសម្រេចចិត្តរបស់រដ្ឋាភិបាលទៅលើថវិកា ថាតើពន្ធអ្វីខ្លះដែលត្រូវយក និង សេវាកម្មអ្វីខ្លះ ដែលត្រូវផ្តល់ជូនប្រជាពលរដ្ឋ និង មានបំណុលចំនួនប៉ុន្មានដែលរដ្ឋាភិបាលជំពាក់ តើបំណុលទាំងនោះជះឥទ្ធិពលយ៉ាងដូចម្តេចខ្លះទៅលើសមភាពសង្គម និង សុខមាលភាពរបស់ប្រជាពលរដ្ឋ រួមទាំងឱកាសសម្រាប់ជនងាយរងគ្រោះ រស់នៅកាន់តែប្រសើរ។ ការជូនដំណឹងរបស់រដ្ឋាភិបាល អំពីការចូលរួមជាសាធារណៈ មានសារៈសំខាន់ណាស់ក្នុងការសំរេចចិត្តណាមួយដែលជះឥទ្ធិពលទៅលើជីវភាពរស់នៅប្រចាំថ្ងៃរបស់ពួកគេ។

ការអង្កេតការផ្សព្វផ្សាយព័ត៌មានថវិកា គឺជាឧបករណ៍ឯករាជ្យ ប្រៀបធៀប និងសិក្សាស្រាវជ្រាវដោយផ្អែកលើអង្គហេតុជាសាកលតែមួយគត់ ដែលប្រើប្រាស់លក្ខណៈវិនិច្ឆ័យ (ចំនួន ១៤៥ សូចនាករ) ដែលទទួលស្គាល់ជាអន្តរជាតិ ដើម្បីវាយតម្លៃលទ្ធភាពរបស់ សាធារណៈជនក្នុងការទទួលបានព័ត៌មានថវិការបស់រដ្ឋាភិបាល ឱកាសផ្លូវការ សម្រាប់សាធារណៈជន ចូលរួមក្នុងដំណើរការរៀបចំថវិកាជាតិ និងតួនាទីរបស់ស្ថាប័នត្រួតពិនិត្យថវិកា រួមមានដូចជា៖ស្ថាប័ន នីតិបញ្ញត្តិ និងអាជ្ញាធរសវនកម្ម ក្នុងដំណើរការនៃការរៀបចំថវិកា។

ការស្ទង់មតិនេះជួយអង្គការសង្គមស៊ីវិលមូលដ្ឋាន វាយតម្លៃ និងពិភាក្សាជាមួយ រដ្ឋាភិបាល ទៅលើការរាយការណ៍ និងការប្រើប្រាស់ថវិកាសាធារណៈ។ ការអង្កេតការផ្សព្វផ្សាយព័ត៌មានថវិកាលើកទី ៧ នេះធ្វើឡើងនៅក្នុង ១១៧ ប្រទេស។ សម្រាប់ប្រទេសកម្ពុជា វាគឺជាការសិក្សាលើកទី៦ ដែលបានចាប់ផ្តើមពីឆ្នាំ ២០០៨។

**សម្រាប់ព័ត៌មានបន្ថែមរួមទាំង វិធីសាស្រ្តស្ទង់មតិ សន្ទស្សន៍នៃការផ្សព្វផ្សាយព័ត៌មានថវិការបាយការណ៍សាកលឆ្នាំ២០១៩ លទ្ធផលនៃការស្ទង់មតិរបស់ប្រទេសនីមួយៗ និងទិន្នន័យផ្សេងៗសូមចូលទៅកាន់គេហទំព័រ**
www.internationalbudget.org/open-budget-survey

បកប្រែក្រៅផ្លូវការដោយវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា

# តម្លាភាពថវិកា

ផ្នែកនេះសន្ទស្សន៍នៃការផ្សព្វផ្សាយព័ត៌មានថវិកា (OBS) បានយកចិត្តទុកដាក់ទៅលើការទទួលបានព័ត៌មានជាសាធារណៈ និងរបៀបដែលរដ្ឋាភិបាលបង្កើនការចំណាយទៅលើធនធានសាធារណៈ។ សន្ទស្សន៍នៃការផ្សព្វផ្សាយព័ត៌មានថវិកានេះ វាយតម្លៃទៅលើព័ត៌មានដែលអាចរកបានលើប្រព័ន្ធផ្សព្វផ្សាយទាន់ពេលវេលា និង ផ្សព្វផ្សាយ ឯកសារព័ត៌មានថវិកា សំខាន់ទាំង ៨ ដែលមានសូចនាករចំនួន១០៩។ ពិន្ទុរបស់ប្រទេស នីមួយៗចាប់ពី ០ ដល់ ១០០។ ពិន្ទុតម្លាភាពថវិកា ៦១ ឬក៏លើសពីសូចនាករខាងលើនេះ មានន័យថាប្រទេសនោះបានផ្សព្វផ្សាយព័ត៌មានថវិកាបានគ្រប់គ្រាន់ដើម្បីគាំទ្រដល់ការពិភាក្សាអំពីថវិកាជាសាធារណៈ។

ពិន្ទុតម្លាភាពថវិកា ប្រទេសកម្ពុជាទទួលបាន **៣២** លើ ១០០

## តម្លាភាពថវិកាក្នុងប្រទេសកម្ពុជា ប្រៀបធៀបទៅនឹងប្រទេសដទៃក្នុងតំបន់

**ប្រទេសកម្ពុជាស្ថិតក្នុង ចំណាត់ថ្នាក់ ៨៦ ក្នុងចំណោម ១១៧ ប្រទេស**






# តើពិន្ទុតម្លាភាពថវិការបស់កម្ពុជាមានការវិវឌ្ឍន៍យ៉ាងដូចម្ដេច?




## ឯកសារដែលអាចស្វែងរកបានជាសាធារណៈនៅកម្ពុជា

● មានផ្សព្វផ្សាយដល់សាធារណៈជន
◐ ផ្សព្វផ្សាយយឺត ឬ មិនបានដាក់លើបណ្ដាញអ៊ីនធឺណេត ឬ ផលិតសម្រាប់ប្រើប្រាស់ផ្ទៃក្នុងស្ថាប័ន
⊘ មិនបានផលិត

| ឯកសារ | 2010 | 2012 | 2015 | 2017 | 2019 |
|---|---|---|---|---|---|
| របាយការណ៍បុរេថវិកា | ● | ● | ● | ● | ● |
| សេចក្ដីព្រាងច្បាប់ថវិកា | ◐ | ◐ | ◐ | ◐ | ● |
| ថវិកាដែលបានអនុម័ត | ● | ● | ● | ● | ● |
| របាយការណ៍ថវិកាសម្រាប់ប្រជាពលរដ្ឋ | ⊘ | ⊘ | ◐ | ● | ● |
| របាយការណ៍ក្នុងឆ្នាំ | ● | ● | ◐ | ● | ● |
| របាយការណ៍ពាក់កណ្ដាលឆ្នាំ | ◐ | ◐ | ◐ | ● | ● |
| របាយការណ៍បំណាច់ឆ្នាំ | ● | ● | ⊘ | ◐ | ● |
| របាយការណ៍សវនកម្ម | ◐ | ◐ | ⊘ | ● | ● |

# តើឯកសារថវិកាសំខាន់ៗដែលកម្ពុជាផ្សព្វផ្សាយមាន លក្ខណៈទូលំទូលាយដល់សាធារណៈជនកម្រិតណា?

- 61-100 / 100
- 41-60 / 100
- 1-40 / 100

| ឯកសារថវិកា សំខាន់ៗ | គោលបំណងនៃឯកសារ និងខ្លឹមសារ | ការវាយតម្លៃប្រចាំឆ្នាំ | ការដាក់ពិន្ទុ |
|---|---|---|---|
| របាយការណ៍បុរេថវិកា | បង្ហាញពីការវាស់វែងទូលំទូលាយជាមុនដូចជាឯកសារស្តីពីសេចក្តីព្រាងច្បាប់ថវិកាប្រចាំឆ្នាំរបស់រដ្ឋាភិបាល, សេចក្តីព្រាងការព្យាករណ៍សេដ្ឋកិច្ចរបស់រដ្ឋាភិបាលនិងឯកសារស្តីពីចំណូល ចំណាយ និងបំណុល | 2019 | 56 |
| សេចក្តីព្រាងច្បាប់ថវិកាប្រចាំឆ្នាំ | ព័ត៌មានលំអិតស្តីអំពីប្រភពចំណូល,ការវិភាជន៍ថវិកាទៅគ្រប់ក្រសួង សំណើផ្លាស់ប្តូរគោលនយោបាយ និងព័ត៌មានសំខាន់ជាច្រើនទៀត ដើម្បីដឹងអំពីស្ថានភាពប្រចាំឆ្នាំរបស់ប្រទេសដែលត្រូវបានដាក់ជូនដោយស្ថាប័ននីតិប្រតិបត្តិ និងអនុម័តដោយស្ថាប័ននីតិបញ្ញត្តិ | 2019 | 14 |
| ថវិកាដែលបានអនុម័ត | ឯកសារថវិកានេះត្រូវបានអនុម័តដោយស្ថាប័ននីតិបញ្ញត្តិ | 2018 | 84 |
| របាយការថវិកាសម្រាប់ប្រជាពលរដ្ឋ | សេចក្តីព្រាងច្បាប់ថវិកាប្រចាំឆ្នាំរបស់រដ្ឋាភិបាលឬថវិកាដែលបានអនុម័តរដ្ឋាភិបាលគួរតែរៀបចំឡើងមានឱ្យលក្ខណៈសាមញ្ញ និងងាយយល់ជាងមុនសម្រាប់បង្ហាញដល់សាធារណៈជន | 2017-2018 | 33 |
| របាយការណ៍ក្នុងឆ្នាំ | ផ្សព្វផ្សាយព័ត៌មានស្តីអំពីការប្រមូលចំណូល និងចំណាយជាក់ស្តែងនិងបំណុលដែលកើតឡើងជាប្រចាំត្រីមាសឬប្រចាំខែ | 2018 | 67 |
| របាយការណ៍ពាក់កណ្តាលឆ្នាំ | ធ្វើបច្ចុប្បន្នភាពទូលំទូលាយស្តីការអនុវត្តថវិកានៅពាក់កណ្តាលឆ្នាំ រួមទាំងការពិនិត្យឡើងវិញនូវការព្យាករណ៍សេដ្ឋកិច្ច និងធ្វើបច្ចុប្បន្នភាពស្តីអំពីលទ្ធផលនៃការព្យាករណ៍ថវិកា . | 2018 | 48 |
| របាយការណ៍បញ្ចប់ឆ្នាំ | របាយការណ៍ចុងឆ្នាំគួរតែបង្ហាញស្ថានភាពគណនីថវិការដ្ឋាភិបាល និងការវាយតម្លៃអំពីបច្ចុប្បន្នភាពសមិទ្ធផលដែលជាគោលដៅនៃគោលនយោបាយថវិកា . | 2017 | 33 |
| របាយការណ៍សវនកម្ម | ផ្សព្វផ្សាយដោយស្ថាប័នសវនកម្មកំពូល។ របាយការណ៍នេះត្រួតពិនិត្យមើលព័ត៌មានពេញលេញស្តីអំពីគណនីបញ្ចប់ឆ្នាំរបស់រដ្ឋាភិបាល . | 2016 | 43 |

**ពិន្ទុតម្លាភាពថវិកា ក្នុងឆ្នាំ២០១៩**

**កម្ពុជាទទួលបាន៣២ពិន្ទុ ខ្ពស់ជាងឆ្នាំ ២០១៧**

## តើសន្ទស្សន៍នៃការផ្សព្វផ្សាយព័ត៌មានថវិកាមានការវិវឌ្ឍន៍យ៉ាងដូចម្តេចខ្លះនៅក្នុងឆ្នាំ២០១៩?

កម្ពុជាបានបង្កើនការផ្សព្វផ្សាយព័ត៌មានថវិកាតាមរយៈ ៖

- ផ្សព្វផ្សាយរបាយការណ៍ចុងឆ្នាំ និងសេចក្តីព្រាងច្បាប់ថវិកាប្រចាំឆ្នាំរបស់រដ្ឋាភិបាល មួយចំនួននៅលើប្រព័ន្ធផ្សព្វផ្សាយ

## អនុសាសន៍

ដើម្បីពង្រឹងតម្លាភាពថវិកា កម្ពុជាគួរតែផ្តល់អាទិភាពទៅលើការអនុវត្តដូចខាងក្រោម ៖

- ផ្សព្វផ្សាយ សេចក្តីព្រាងច្បាប់ថវិកាប្រចាំឆ្នាំរបស់រដ្ឋាភិបាល និងឯកសារជំនួយនៅលើប្រព័ន្ធផ្សព្វផ្សាយមុនពេលរដ្ឋសភាអនុម័តថវិកាប្រចាំឆ្នាំ
- ផ្សព្វផ្សាយរបាយការណ៍បំណុលចុងឆ្នាំនិងការអនុវត្តបំណុល
- ស្វែងរកធាតុចូលពីសារធារណៈជនដើម្បីដាក់បញ្ចូលក្នុងរបាយការណ៍ថវិកាសម្រាប់ប្រជាពលរដ្ឋ
- ពង្រឹងការតាមដានរបាយការណ៍សវនកម្ម និងតាមដានបញ្ហាប្រតិបត្តិការណ៍ដែលឆ្លើយតបទៅនឹងលទ្ធផលសវនកម្ម



# ការចូលរួមជាសាធារណៈ

កម្លាភាពថវិកាតែមួយមិនគ្រប់គ្រាប់ដើម្បី ពង្រឹងអភិបាលកិច្ចល្អនោះទេ។ ការចូលរួមពីសាធារណៈជនមានសារៈសំខាន់ណាស់  ដើម្បីទទួលបានលទ្ធផលជាវិជ្ជមាននៃតម្លាភាពថវិកា។

សន្ទស្សន៍នៃការផ្សព្វផ្សាយព័ត៌មានថវិកា  វាយតម្លៃទៅលើឱកាសដែលរដ្ឋាភិបាលផ្តល់អោយសាធារណៈជនក្នុងការចូលរួមគ្រប់ដំណាក់កាលនៃដំណើរការថវិកា។ សន្ទស្សន៍នៃការផ្សព្វផ្សាយព័ត៌មានថវិកា ត្រួតពិនិត្យទៅលើការអនុវត្តរបស់រដ្ឋាភិបាលកណ្តាល អង្គនីតិបញ្ញត្តិអាជ្ញាធរសវនកម្មកំពូលដោយប្រើប្រាស់សូចនាករចំនួន ១៨ ផ្អែកទៅលើ **គោលការណ៍នៃការចូលរួមជាសាធារណៈក្នុងគោលនយោបាយប្រចាំឆ្នាំ** របស់គម្រោងគំនិតផ្តួចផ្តើមសាកលដើម្បីតម្លាភាពសារពើពន្ធ ។ ចំនួនពិន្ទុសម្រាប់ប្រទេសនីមួយៗចាប់ពី ០ ដល់ ១០០។

ពិន្ទុការចូលរួមជាសាធារណៈ ប្រទេសកម្ពុជាទទួលបាន **៦** លើ ១០០។

### ការចូលរួមជាសាធារណៈរបស់ប្រទេសកម្ពុជា ប្រៀបធៀបនឹងប្រទេសដទៃក្នុងតំបន់

| | |
|---|---|
| ចំណាត់ថ្នាក់សាកល | ១៤ |
| ប្រទេសហ្វីលីពីន | ៣១ |
| ប្រទេសឥណ្ឌូនេស៊ី | ២០ |
| ប្រទេសម៉ាឡេស៊ី | ១៧ |
| ប្រទេសវៀតណាម | ១១ |
| ប្រទេសកម្ពុជា | ៦ |
| ប្រទេសទីម័រខាងកើត | ៦ |
| ប្រទេសមីយ៉ាន់ម៉ា | ០ |

០ តិចតួច ៦១ ទូលំទូលាយ ១០០

# ឱកាសសម្រាប់សាធារណៈជនចូលរួម ក្នុងដំណើរការនៃការរៀបចំថវិកា

| 0 /100 | 11 /100 | 17 /100 | 0 /100 |
|---|---|---|---|
| ការរៀបចំថវិកា (ស្ថាប័ននីតិប្រតិបត្តិ) | ការអនុម័តថវិកា (ស្ថាប័ននីតិបញ្ញត្តិ) | ការអនុវត្តថវិកា (ស្ថាប័ននីតិប្រតិបត្តិ) | សវនកម្ម (ស្ថាប័នសវនកម្មកំពូល) |

តិចតួច:0-40   នៅមានកម្រិត : 41-60  គ្រប់គ្រាន់: 61-100

## ឯកសាដែលអាចស្វែងរកបានជាសាធារណៈនៅកម្ពុជា

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានផ្សព្វផ្សាយ និងប្រឹក្សាយោបល់អំឡុងពេលការអនុវត្តថវិកាជាសាធារណៈ ប៉ុន្តែដើម្បីពង្រឹងការចូលរួមរបស់សាធារណៈជនក្នុងដំណើរការថវិកាគួរតែផ្តល់អាទិភាពលើការអនុវត្តដូចខាងក្រោម៖**

- សាកល្បងយន្តការនៃការចូលរួមជាសាធារណៈដើម្បីប្រជាពលរដ្ឋមានឱកាលចូលរួមក្នុងដំណើរការនៃការរៀបចំថវិកា
- បង្កើតការផ្សព្វផ្សាយតាមរយៈវេទិកាសាធារណៈ និងយន្តការផ្សេងៗ ដើម្បីជម្រុញសាធារណៈជនចូលរួម ត្រួតពិនិត្យ អនុវត្ត ថវិកាដែលបានអនុម័ត
- ចូលរួមយ៉ាងសកម្មជាមួយជនងាយរងគ្រោះ និង តំណាងសហគមន៍ ដោយផ្ទាល់ឬតាមរយៈសង្គមស៊ីវិលដែលតំណាងអោយជនងាយរងគ្រោះ ឬ សហគមន៍

**រដ្ឋសភាកម្ពុជាបានផ្សព្វផ្សាយ ការអនុម័តថវិកាប្រចាំឆ្នាំ ទោះជាយ៉ាងនេះក្តី រដ្ឋសភាកម្ពុជាគួរតែយកចិត្តទុកដាក់ទៅលើការអនុវត្តសកម្មភាពអាទិភាពមួយចំនួនដូចខាងក្រោម៖**

- អនុញ្ញាតិអោយសាធារណៈជន និងអង្គកាសង្គមស៊ីវិល ធ្វើជាសក្ខីកម្មលើ សេចក្តីព្រាងច្បាប់ថវិកាដែលនឹងអនុម័ត
- អនុញ្ញាតិអោយសាធារណៈជន និងអង្គកាសង្គមស៊ីវិល ធ្វើជាសក្ខីកម្មរបាយការណ៍សវនកម្ម

**អាជ្ញាធរសវនកម្មជាតិកម្ពុជាគួរតែផ្តល់អាទិភាពទៅលើការអនុវត្តខាងក្រោមដើម្បីពង្រឹងការចូលរួមជាសាធារណៈក្នុងដំណើការរៀបចំថវិកា៖**

- ផ្សព្វផ្សាយយន្តការ ដើម្បីលើកកម្ពស់សាធារណៈជនចូលរួម កម្មវិធីសវនកម្ម និង រួមចំណែកជួយការអង្កេតលើស្ថាប័នសវនកម្មពាក់ព័ន្ធ

# ការត្រួតពិនិត្យថវិកា

សន្ទស្សន៍នៃការផ្សព្វផ្សាយព័ត៌មានថវិកា (OBS) មានតួនាទីត្រួតពិនិត្យ ស្ថាប័ននីតិបញ្ញត្តិ និង ស្ថាប័នសវនកម្មកំពូល ក្នុងដំណើរការរៀបចំថវិកាជាតិ និងវិសាលភាពនៃការត្រួតពិនិត្យ។ ពិន្ទុនៃការត្រួតពិនិត្យថវិកា ចាប់ពី 0 ដល់ ១០០ ដោយប្រើប្រាស់សូចនាករចំនួន ១៨។ ការស្ទង់មតិនេះ ប្រមូលព័ត៌មាន ពីស្ថាប័នឯករាជ្យ។

ស្ថាប័ននីតិប្បញ្ញត្តិ និងស្ថាប័ន សវនកម្មកំពូល កម្ពុជាផ្តល់ការត្រួតពិនិត្យ ក្នុងដំណើការរៀបចំថវិកានៅមានកម្រិតនៅឡើយ។ កម្ពុជាទទួលបានពិន្ទុការត្រួតពិនិត្យថវិកាស្ថាប័ន ៥០ លើ ១០០ ការត្រួតពិនិត្យថវិកាស្ថាប័ននីមួយៗបានបង្ហាញដូចខាងក្រោម៖

**ការត្រួតពិនិត្យ ស្ថាប័ននីតិបញ្ញត្តិ**




**ការត្រួតពិនិត្យ ស្ថាប័នសវនកម្ម**




តិចតួច: 0-40 នៅមានកម្រិត: 41-60 គ្រប់គ្រាន់: 61-100

# អនុសាសន៍

**រដ្ឋសភាកម្ពុជា ផ្តល់ឱកាលតិចតួចបំផុតដល់សាធារណៈជន ក្នុងការចូលរួមត្រួតពិនិត្យការធ្វើផែនការ ក្នុងដំណាក់កាលរដ្ឋថវិកា និង ការអនុវត្តថវិកា។ ដើម្បីពង្រឹងការត្រួតពិនិត្យថវិកាសភាជាតិកម្ពុជា គួរតែផ្តល់អាទិភាពលើការអនុវត្តដូចខាងក្រោម៖**

- ស្ថាប័ននីតិបញ្ញត្តិគួរតែពិភាក្សាវែកញែកលើគោលនយោបាយថវិកាមុនពេល សេចក្តីព្រាងច្បាប់ថវិកាប្រចាំឆ្នាំរបស់រដ្ឋាភិបាល បានអនុម័តលើអនុសាសន៍សម្រាប់ការអនុវត្តន៍ថវិកាពេលខាងមុខ
- គណៈកម្មាធិការស្ថាប័ននីតិប្បញ្ញត្តិ គួតែត្រួតពិនិត្យ លើការប្រតិបត្តិការសំណើថវិកា ផ្សព្វផ្សាយរបាយការណ៍តាមប្រព័ន្ធផ្សព្វផ្សាយ
- គណៈកម្មាធិការនៃស្ថាប័ននីតិបញ្ញត្តិ គួតែត្រួតពិនិត្យលើការអនុវត្តថវិកាក្នុងឆ្នាំថវិកា និងផ្សព្វផ្សាយរបាយការណ៍លទ្ធផលតាមប្រព័ន្ធផ្សព្វផ្សាយ

- ធានាថាស្ថាប័ននីតិបញ្ញត្តិ អនុវត្តការពិគ្រោះយោបល់
មុនពេលប្រតិបត្តិការចំណាយលើចំណូលដែលមិនបានគ្រោងទុក ឬក៏កាត់បន្ថយ
ចំណាយដោយសារខ្វះខាតចំណូល
- គណៈកម្មាធិការនៃស្ថាប័ននីតិបញ្ញត្តិ គួរតែត្រួតពិនិត្យរបាយការណ៍សវនកម្ម និងផ្សព្វផ្សាយ
របាយការណ៍លទ្ធផលតាមប្រព័ន្ធផ្សព្វផ្សាយ

**ដើម្បីរឹតបន្តឹងឯករាជ្យភាព និង ការត្រួតពិនិត្យស្ថាប័នសវនកម្ម អាជ្ញាធរសវនកម្មជាតិកម្ពុជា គួរតែអនុវត្តសកម្មភាពតាមអនុសាសន៍ដូចខាងក្រោម៖**

- ធានាថាដំណើរការសវនកម្មត្រូវតែត្រួតពិនិត្យដោយ ស្ថាប័នឯករាជ្យ។

## អនុវត្តការបង្កើតស្ថាប័នហិរញ្ញវត្ថុឯករាជ្យ

កម្ពុជាមិនទាន់មានស្ថាប័នហិរញ្ញវត្ថុឯករាជ្យនៅឡើយ។ស្ថាប័នហិរញ្ញវត្ថុឯករាជ្យត្រូវបាន
គេទទួលស្គាល់ថាជាស្ថាប័នឯករាជ្យ ដែលផ្តល់ព័ត៌មានឯករាជ្យទៅកាន់សភាក្នុងដំណើរ
ការថវិកា។

**សូចនាករទាំងនេះមិនដាក់ពិន្ទុនៅក្នុង
សន្ទស្សន៍នៃការផ្សព្វផ្សាយព័ត៌មានថវិកាទេ។*

# វិធីសាស្ត្រ

- ឯកសារ ព្រឹត្តការណ៍ និងសកម្មភាព ដែលបានប្រព្រឹត្តទៅមុនថ្ងៃ ៣០ ខែធ្នូ ឆ្នាំ ២០១៨ ប៉ុណ្ណោះដែលត្រូវបានវាយតម្លៃ នៅក្នុងសន្ទស្សន៍នៃការផ្សព្វផ្សាយព័ត៌មានថវិកា ឆ្នាំ ២០១៩។
- ការស្ទង់មតិនេះបានពឹងផ្អែកទាំងស្រុងទៅលើកំរងសំណួរ ដែលបានឆ្លើយដោយ អ្នកឯកទេសថវិកាឯករាជ្យរបស់ប្រទេស ដែលមានដូចខាងក្រោមៈ
- លោក អ៊ុក វណ្ណារ៉ា   លោក ស៊ុន យូរ៉ា និង កញ្ញា អ៊ុច សុវណ្ណាលំយ

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា

អាសយដ្ឋាន #9-11 ផ្លូវលេខ ៤៧៦ សង្កាត់ទួលទំពូង ខណ្ឌចំការមន P.O.Bo 2295

ភ្នំពេញ-៣ ប្រទេសកម្ពុជា

oukvannara@ngoforum.org.kh

- ដើម្បីពង្រឹងការសិក្សាស្រាវជ្រាវបន្ថែមទៀត សេចក្តីព្រាងកម្រងសំណួរសន្ទស្សន៍នៃការផ្សព្វផ្សាយព័ត៌មានថវិកា ត្រូវបានត្រួតពិនិត្យដោយ អ្នកជំនាញឯករាជ្យអនាមិក។ សម្រាប់ប្រទេសកម្ពុជាតំណាងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។